# អាគីឆ្កែខ្ញុំ



ចម្រៀងកុមារមត្តេយ្យ ភាគ១

©រចនារូបភាពដោយ មីតា រ៉េកូ (MITA Reiko) (©រក្សាសិទ្ធិគ្រប់យ៉ាង)
©Illustrated by MITA Reiko
絵：三田 玲子

បោះពុម្ពលើកទី១ ឆ្នាំ១៩៩៧ នៅភ្នំពេញ (1st edition, 1997)
បោះពុម្ពលើកទី២ ឆ្នាំ១៩៩៨ នៅភ្នំពេញ (2nd edition, 1998)
បោះពុម្ពលើកទី៣ ឆ្នាំ១៩៩៩ នៅភ្នំពេញ (3rd edition, 1999)
បោះពុម្ពលើកទី៤ ឆ្នាំ២០០៣ នៅភ្នំពេញ (4th edition, 2003)
បោះពុម្ពលើកទី៥ ឆ្នាំ២០០៥ នៅភ្នំពេញ (5th edition, 2005)
បោះពុម្ពលើកទី៦ ឆ្នាំ២០០៦ នៅភ្នំពេញ (6th edition, 2006)
បោះពុម្ពលើកទី៧ ឆ្នាំ២០១០ នៅភ្នំពេញ (7th edition, 2010)
បោះពុម្ពលើកទី៨ ឆ្នាំ២០១១ នៅភ្នំពេញ (8th edition, 2011)

បោះពុម្ពលើកទី៩ដោយ : អង្គការគាំពារកុមារខ្មែរ(CYK)
នៅភ្នំពេញ ខែកក្កដា ឆ្នាំ២០១២
មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុន
សម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ
ចំនួន : ៣២០ក្បាល
លេខ : CYK N10019
រោងពុម្ព : JSRC Printing House

発行 ：特定非営利活動法人 幼い難民を考える会
2012年7月（9刷）プノンペン
協力 ：国際ボランティア貯金
部数 ：320冊
番号 ：CYK N10019
印刷所：JSRC Printing House

ហាមចំលងផ្នែកណាមួយនៃសៀវភៅនេះ ជាប្រយោជន៍ផ្ទាល់ខ្លួន ឬលក់ដូរដោយគ្មានការអនុញ្ញាតិពីអង្គការគាំពារកុមារខ្មែរ
No part of this book should be copied for commercial use without a permission of Caring for Young Khmer

# មាតិការឿង


ឱផ្កាឈូកអើយ ........ ១

ហាត់ប្រាណ ........ ៣

វិញ្ញាណទាំងប្រាំ ........ ៥

សន្ទូងបៃតង ........ ៧

យើងពាក់មួក ........ ៩

អាគីផ្អែខ្ញុំ ........ ១១

មេមាន់ពងរាល់ថ្ងៃ ........ ១៣

ទៅណាកូនក្ដាម ........ ១៥

កង្កែបនៅលើមាត់បឹង ........ ១៧

កុកមួយកុកពីរ ........ ១៩

យើងខ្ញុំជាកុមារមត្តេយ្យ ........ ២១

សត្វទីទុយ ........ ២៣

# ឱផ្កាឈូកអើយ

លំនាំបទ : អុំទូក

បងអុំទូកទៅ អឺៗៗ អើយ ឮសូរគ្រូកៗ
ទៅបេះៗ ផ្កាឈូក អឺៗៗ អើយ ដុះក្នុងបឹងកក់ ។

ឱផ្កាឈូកអើយ អឺៗៗ អើយ ដុះចេញពីភក់
គួរធុំៗ អាក្រក់ អឺៗៗ អើយ ម្ដេចឡើយឈ្ងុយឈ្ងប់ ។

ទាំងមើមក្រអៅ អឺៗៗ អើយ ផ្លែម្សៅឈ្ងុយសព្វ
ដុះចេញៗ ពីល្បប់ អឺៗៗ អើយ ត្រឡប់ជាល្អ ៕



# ហាត់ប្រាណ

លំនាំបទ : សារិកាកែវ

ព្រះអាទិត្យរះហើយ នាំគ្នាលើកដៃ កុគីកែកឹត
ព្រះអាទិត្យរះហើយ នាំគ្នាលើកដៃ
ទទួលពន្លឺ រាងកាយមាំមួន អឺៗៗ អឺយ ។

ពត់ខ្លួនទៅមុខ ពត់ខ្លួនទៅក្រោយ កុគីកែកឹត
ពត់ខ្លួនទៅមុខ ពត់ខ្លួនទៅក្រោយ
ខ្យល់បក់មកហើយ នាំគ្នារែរាំ អឺៗៗ អឺយ ។

ហាត់ប្រាណរាល់ព្រឹក រាងកាយមាំល្អ កុគីកែកឹត
ហាត់ប្រាណរាល់ព្រឹក រាងកាយមាំល្អ
សុខភាពបវរ ប្រាជ្ញាភ្លឺថ្លា អឺៗៗ អឺយ ៕



# វិញ្ញាណទាំងប្រាំ

ខ្ញុំមានមាត់សំរាប់និយាយ បើសប្បាយចិត្តខ្ញុំច្រៀងលេង
មានត្រចៀកស្តាប់សូរសំលេង មានទាំងធ្មេញទុកទំពាអាហារ
មែនហើយទុកទំពាអាហារ ។
ច្រមុះពិតហិនក្លិននានា មានមុខងារសំខាន់អស្ចារ្យ
យើងស្រូបខ្យល់ចូលក្នុងឱរ៉ា ទ្រទ្រង់កាយាឱ្យបានរស់រាន
មែនហើយឱ្យបានរស់រាន ។
ភ្នែកទាំងគូសំរាប់មើលគេ ជើងទាំងទ្វេសំរាប់ដើរឈាន
ដៃទាំងពីរជាកាយវិញ្ញាណ បើចាប់កាន់ដឹងត្រជាក់ឬក្តៅ
មែនហើយដឹងត្រជាក់ឬក្តៅ ៕



# សន្ទូងបៃតង

សន្ទូងបៃតង លាស់ស្រស់បំព្រង ដូចព្រំស្រងាត់
យើងខ្ញុំប្រជា ការពារប្រយ័ត្ន កុំឱ្យក្លាមកាត់
នាំបាត់ផលស្រូវ ៕ (ច្រៀង២ដង)

# សន្ទូងបៃតង (លំនាំបទ "កុកហើរតែឯង")

សន្ទូងបៃតង (២ដង) លាស់ស្រស់បំព្រង (២ដង) ដូចព្រំស្រងាត់
យើងខ្ញុំប្រជា ការពារប្រយ័ត្ន កុំឱ្យក្លាមកាត់ (២ដង) នាំបាត់ផលស្រូវ៕
(ច្រៀង២ដង)



# យើងពាក់មួក

យើងពាក់មួក ពាក់ហើយយកវិញ
មួកយើងទិញ យើងទិញពីផ្សារ
បើយើងចង់បាន ទៅសុំម៉ាក់ប៉ា
មួកនេះណា ជារបស់ខ្ញុំ ។

អ្នកណាបានទទេ គួរឱ្យគេចង់សើច
អ្នកណាបានទទេ គួរខ្មាសគេរាល់គ្នា ៕
(ច្រៀង២ដង)



# អាគីផ្កែខ្ញុំ

អាគីផ្កែខ្ញុំ វានៅចាំផ្ទះ
វាចេះសំពះ ចេះដើរជើងពីរ
បើចង់ប្រើវា ទាល់តែឱ្យនំស៊ី
ទើបវាដើរជើងពីរ បក់កន្ទុយឱ្យមើល ៕
(ច្រៀង២ដង)



# មេមាន់ពងរាល់ថ្ងៃ

មេមាន់ពងបានម្តងមួយ ពងម្តងមួយ ពងម្តងមួយ
មេមាន់ពងបានរាល់ថ្ងៃ មួយថ្ងៃមាន់ពងបានមួយ
មេមាន់ពងបានរាល់ថ្ងៃ ពីរថ្ងៃមាន់ពងបានពីរ
មេមាន់ពងបានរាល់ថ្ងៃ បីថ្ងៃមាន់ពងបានបី
មេមាន់ពងបានរាល់ថ្ងៃ បួនថ្ងៃមាន់ពងបានបួន
មេមាន់ពងបានរាល់ថ្ងៃ ប្រាំថ្ងៃមាន់ពងបានប្រាំ ៕



# ទៅណាកូនក្ដាម

ក្ដាមអើយៗ នាំកូនវារទៅណាដែរ
ទៅស្រែៗ នៅក្បែរជើងភ្នំនុះន៎
ទឹកច្រើនសម្បូរហូរហៀរសប្បាយ ។

ទាំងហ្វូងៗ តូចៗទៅណា
ម៉ាក់ខ្ញុំៗ គាត់នាំដើរលេងកំសាន្ដ
ដល់ឃ្លានខ្ញុំមានចំណីអាស្រ័យ ៕



# កង្កែបនៅលើមាត់បឹង

កែប! កែប! កង្កែប កែប! កង្កែបគឺកង្កែបញី
កែប! កែប! កង្កែប កែប! កង្កែបគឺកង្កែបឈ្មោល ។
នៅលើមាត់បឹង ប្រឹងសម្លឹងសម្លក់ទឹកថ្លា
កង្កែបឈ្មោលញី មុជវក់វីប្រុងប្រៀបអាត្មា ។
ភ្លុងៗ ភ្លីង ភ្លុងៗ ភ្លីង ភ្លុង កង្កែបលោតភ្លុង (២ដង)
កង្កែបក្មេងៗ ស្រែកច្រៀងលេងសំលេងក្បោះក្បាយ
ស្រែកច្រៀងតគ្នា រាល់វេលាវាសែនសប្បាយ ។
កែប! កែប! កង្កែប កែប! កង្កែបគឺកង្កែបញី
កែប! កែប! កង្កែប! កែប! កង្កែបគឺកង្កែបឈ្មោល ។
ញី ឈ្មោល ៕



# កុកមួយកុកពីរ

កុកមួយកុកពីរកុកបី ទៅចាប់ត្រីបបួលកុកបួន
កុកប្រាំមិនស្ងួរស្រួលខ្លួន ឱ្យកុកបួនហៅកុកប្រាំមួយ ។

លេខមួយលេខពីរលេខបី ទៅចាប់ត្រីបបួលលេខបួន
លេខប្រាំមិនស្ងួរស្រួលខ្លួន ឱ្យលេខបួនហៅលេខប្រាំមួយ ៕



# យើងខ្ញុំជាកុមារមត្តេយ្យ

យើងខ្ញុំជាកុមារមត្តេយ្យ ត្រូវឃ្លាតខ្មីខិតខំសិក្សា
ដាច់ឆ្នាំពេលណា កុមារឡើងថ្នាក់ទាំងអស់
សារ៉ាវ៉ាន់ទៅមុខ ទៅមុខៗ សារ៉ាវ៉ាន់
រាំទៅមុខ សារ៉ាវ៉ាន់ អឺយ ។

យប់នេះមេឃភ្លឺស្រឡះ ខ្យល់អាកាសបក់មករងា
គន់មើលដួងចន្ទ្រា ចែងចាំងរស្មីភ្លឺថ្លា
សារ៉ាវ៉ាន់ថយក្រោយ ថយក្រោយៗ សារ៉ាវ៉ាន់
រាំថយក្រោយ សារ៉ាវ៉ាន់ អឺយ ៕



# សត្វទីទុយ

ខ្ញុំឃើញទីទុយមួយភ្នែកធំ
ស្រែកយំពីលើដើមជ្រៃ
ឮសូរសម្រែកសត្វមៀមព្រៃ
ឃ្មាតខ្មីយំឆ្លាស់ឆ្លើយឆ្លង ។
ទីទុយ! ទីទុយ! ទីទុយ! ទីទុយ!
(ច្រៀង២ដង)

